**ចំណេះដឹង និងបទពិសោធន៍ស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច**

**ត្រូវបានផ្ទេរបន្តអោយមន្ត្រីពាក់ព័ន្ធថ្នាក់ខេត្ត ស្រុក**

**ភ្នំពេញ ថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១០**

ដើម្បីពង្រឹង និងលើកកំពស់ការអនុវត្តការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៅថ្នាក់ក្រោមជាតិ ក្រុមការងារកិច្ចការពារសុវត្ថិភាពនៃលេខាធិការដ្ឋាន គ.ជ.អ.ប កាលពីថ្ងៃទី១៨ ដល់ថ្ងៃ២៨ ខែឧសភា ឆ្នាំ២០១០ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ដល់មន្ត្រីសម្របសម្រួលខេត្ត ស្រុក មន្ត្រីគាំទ្របច្ចេកទេស មន្ត្រីបង្គោលកិច្ចការពារសុវត្ថិភាពថ្នាក់ខេត្ត ទីប្រឹក្សារដ្ឋបាលមូលដ្ឋាន និងទីប្រឹក្សាហេដ្ឋារចនាសម្ព័ន្ធ ក្នុងគោលបំណងចែករំលែកចំណេះដឹង មេរៀន និងបទពិសោធន៍ ដើម្បីបង្កើនសមត្ថភាពក្នុងការអនុវត្តកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច អោយកាន់តែមានប្រសិទ្ធភាពខ្ពស់។

វគ្គបណ្តុះបណ្តាលនេះ ត្រូវបានធ្វើឡើងនៅតាមតំបន់គោលដៅទាំង៤ផ្សេងៗគ្នាគឺៈ (១) តំបន់ព្រះសីហនុ (ខេត្តព្រះសីហនុ កែប កំពត និងកោះកុង) (២) តំបន់កំពង់ស្ពឺ (ខេត្តកំពង់ស្ពឺ កណ្តាល តាកែវ ស្វាយរៀង ព្រៃវែង កំពង់ឆ្នាំង និងពោធិ៍សាត់) (៣) តំបន់ចេះ (ខេត្តក្រចេះ កំពង់ចាម ស្ទឹងត្រែង រតនគិរី និងមណ្ឌលគិរី) (៤) តំបន់សៀមរាប (ខេត្តសៀមរាប កំពង់ធំ ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ ប៉ៃលិន និងបាត់ដំបង) ដោយមានសិក្ខាកាមចូលរួមចំនួន១៦២ នាក់ (ស្រីចំនួន១៥នាក់)។

វិធីសាស្ត្រអនុវត្តក្នុងវគ្គបណ្តុះបណ្តាលរួមមាន ការធ្វើបទបង្ហាញរបស់អ្នកសម្របសម្រួល ផ្តោតសំខាន់លើការអនុវត្ត ជាក់ស្តែង ដោយបង្ហាញនិងពន្យល់បកស្រាយអំពីដំណើរការរបស់កិច្ចការពារសុវត្ថិភាពនីមួយៗ ការអនុវត្តលំហាត់សាកល្បង ដោយផ្សារភ្ជាប់រវាងគោលការណ៍ណែនាំ និងបទពិសោធន៍ជាក់ស្តែង ការពិភាក្សាជាក្រុម សំណួរ ចម្លើយ ដើម្បីវាយតម្លៃការយល់ដឹងរបស់សិក្ខាកាមតាមរយៈការបំពេញបញ្ជីសំណួរ និងការចែករំលែកចំណេះដឹង និងបទពិសោធន៍ក្នុងចំណោមសិក្ខាកាមទាំងអស់។

ផ្អែកតាមការវាយតម្លៃនៅចុងបញ្ចប់វគ្គបណ្តុះបណ្តាលទាំងបួន សិក្ខាកាមមានការយល់ដឹងអំពីកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច កាន់តែប្រសើរឡើងបើប្រៀបធៀបទៅបណ្តាឆ្នាំមុនៗ។ សិក្ខាកាមមានការយល់ដឹងច្បាស់លើខ្លឹមសារមេរៀន ពីព្រោះរាល់បទបង្ហាញទាំងអស់សុទ្ធតែបានផ្សារភ្ជាប់រវាងគោលការណ៍ណែនាំ និងបទពិសោធន៍ជាក់ស្តែងនៅតាមបណ្តាខេត្តនីមួយៗ ជាពិសេសទម្រង់ទាំងឡាយដែលពាក់ព័ន្ធទៅនឹងកិច្ចការពារសុវត្ថិភាពទាំងបីដែលអាចជួយពង្រឹងដល់ការសិក្សា និងរៀបចំគម្រោងនៅតាមបណ្តាមូលដ្ឋាននៃខេត្តនីមួយៗ ត្រូវបានបង្ហាញណែនាំ និងពិភាក្សាយ៉ាងលំអិត។

ក្រុមការងារកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិចនៃលេខាធិការដ្ឋាន គ.ជ.អ.ប សង្ឃឹមយ៉ាងមុតមាំថា សិក្ខាកាមដែលទទួលបានការបណ្តុះបណ្តាល នឹងចែករំលែកចំណេះដឹង និងបទពិសោធន៍ទាំងនេះបន្តដល់មន្ត្រីពាក់ព័ន្ធផ្សេងៗទៀត និងយកទៅអនុវត្តការងារអោយកាន់តែមានប្រសិទ្ធភាព។

***ព័ត៌មានបន្ថែមសូមធ្វើការទំនាក់ទំនង លោក ផែន រស្មី មន្ត្រីព័ត៌មាន និងទំនាក់ទំនងសាធារណៈ នៃលេខាធិការដ្ឋានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) តាមរយៈ raksmey.phen@ncdd.gov.kh ឬតាមរយៈលេខទូរសព្ទ ០១៧ ៧៩៥ ៦២៣។***